# មេរៀនទី ១១១: ពេត្រុស និងអនទ្រេជួបព្រះយេស៊ូវ

## យ៉ូហាន១:៣៥-៤២

| |
|---|
| **គោលបំណង៖** ព្រះយេស៊ូវគឺជាកូនចៀមនៃព្រះ។ |

| |
|---|
| **ខគម្ពីរចងចាំ៖ យ៉ូហាន ១:៣៦** *“គាត់មើលទៅព្រះយេស៊ូវ ដែលទ្រង់កំពុងតែយាងទៅ ក៏ពោលថា នុ៎ះន៍កូនចៀមនៃព្រះ។”* |

| |
|---|
| **ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)** |
| ព្រះយេស៊ូវទ្រង់ស្គាល់ពួកយើងប្រសើរជាងពួកយើងស្គាល់ខ្លួនឯងទៅទៀត។ ព្រះអង្គក៏អាចជួយយើងឲ្យស្គាល់ទ្រង់បានដែរ។ សូមអានព្រះគម្ពីរ **យ៉ូហាន ១:៣៥-៤២**សារឡើងវិញ។ តើអ្នករៀនបានអ្វីពីព្រះយេស៊ូវនៅពេលដែលអ្នកជួបទ្រង់ជាលើកដំបូង? រៀនបានច្រើនណាស់ត្រូវអត់? ប៉ុន្តែ នៅមានរឿងជាច្រើនទៀតដែលយើងត្រូវតែដឹង។ នៅសប្តាហ៍នេះសូមទូលសុំព្រះឲ្យបង្រៀនអ្នកពីរឿងរ៉ាវថ្មីទៀតអំពីព្រះយេស៊ូវ។ បន្ទាប់មកសូមប្រាប់អ្នកផ្សេងទៀតពីអ្វីដែលអ្នកបានរៀន។ ប្រាកដណាស់ ការចែកចាយរបស់អ្នកគឺពិតជាអាចជួយអ្នកដទៃបាន អ្នកជួយអ្នកដទៃបានប៉ុនណា នោះវាក៏អាចជួយដល់អ្នកបានប៉ុណ្ណោះដូចគ្នាដែរ។ |

| | | | |
|---|---|---|---|
| **ចំរៀង៖** | ១.ខ្ញុំបានសម្រេចចិត្ត | ២.ខ្ញុំដើរតាមព្រះយេស៊ូវ | ៣.ស្តេចលើស្តេច |

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

| |
|---|
| **៣. ល្បែងកំសាន្ត «នាំកុមារទៅជួបព្រះយេស៊ូវ»** |




១. ឲ្យកុមារណាម្នាក់(អាចជាកុមារដែលមានមាឌធំជាងគេក៏បាន) ស្ម័គ្រចិត្តធ្វើជាព្រះយេស៊ូវ ហើយឈរនៅចុងម្ខាងនៃថ្នាក់រៀន

២. កុមារដែលនៅសេសសល់ទាំងប៉ុន្មានត្រូវឈរនៅចុងម្ខាងទៀតនៃថ្នាក់រៀន ហើយពួកគេអាចផ្លាស់ទីបាននៅពេលដែលគ្រូនិយាយចំនួនណាមួយនៃម៉ោង។ ឧទាហរណ៍៖ ប្រសិនបើគ្រូនិយាយថា “៣ម៉ោង” នោះមានន័យថាពួកគេអាចដើរបាន៣ជំហាន។ ប្រសិនបើគ្រូនិយាយថា “៥ម៉ោង” នោះកុមារអាចដើរបាន៥ជំហាន។

៣. គោលបំណងនៃល្បែងនេះគឺដើម្បីចូលទៅជិតព្រះយេស៊ូវ ហើយប៉ះទ្រង់បាន។

៤. កុមារទី១ដែលអាចប៉ះព្រះយេស៊ូវបានមុនគេកុមារនោះជាអ្នកឈ្នះល្បែងនេះ។ ប៉ុន្តែយើងនឹងបន្តលេងល្បែងនេះ រហូតដល់កុមារគ្រប់គ្នាៗបានប៉ះព្រះយេស៊ូវ។

៥.បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា យើងត្រូវតែខិតខំប្រឹងប្រែងឲ្យអស់ពីសមត្ថភាពដើម្បីបានជួបព្រះយេស៊ូវ ពីព្រោះទ្រង់ជាព្រះអង្គសង្គ្រោះរបស់យើងរាល់គ្នា។

## ៤. ការណែនាំមេរៀន

តើមានប្អូនៗណាខ្លះធ្លាប់ទន្ទឹងរង់ចាំម៉ាក់មកពីផ្សារ? ហើយចុះតើមានប្អូនៗណាខ្លះ ធ្លាប់ទន្ទឹងរង់ចាំប៉ាធ្វើដំណើរមកពីឆ្ងាយ? តើការរងចាំនរណាម្នាក់វាយូរណាស់មែនទេ? តើអ្នកនឹងមានអារម្មណ៍ដូចម្តេច នៅពេលដែលការទន្ទឹងរងចាំអ្វីមួយអស់ជាច្រើនឆ្នាំរបស់អ្នកបានមកដល់? នៅក្នុងព្រះគម្ពីរមនុស្សបានធ្វើការរងចាំព្រះអង្គសង្គ្រោះក្នុងការយាងមក ដើម្បីរំដោះពួកគេពីលោកីយ៍នេះពីការរងទុក្ខ។ សាច់រឿងរបស់ព្រះគម្ពីររបស់យើងនៅថ្ងៃនេះគឺថាទីបំផុតប្រជារាស្ត្របានរកឃើញព្រះអង្គសង្គ្រោះហើយ គឺជាកូនចៀមនៃព្រះ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

សាច់រឿងនៅក្នុងព្រះគម្ពីរបានប្រាប់យើងអំពីបុរស៣នាក់គឺ យ៉ូហានបាទីស្ទ ពេត្រុស និងអនទ្រេ។ យ៉ូហាន-បាទីស្ទបានរៀបចំផ្លូវសម្រាប់ព្រះអង្គសង្គ្រោះ ដែលយើងអាចហៅបានថាកូនចៀមនៃព្រះ។ មនុស្សម្នាបានធ្វើការអធិស្ឋានដោយសង្ឃឹមក្នុងចិត្តថា ព្រះអង្គសង្គ្រោះនឹងយាងមកឆាប់ៗ។ ព្រះយេស៊ូវក៏បានឆ្លើយតបនឹងការអធិ-ស្ឋានរបស់ពួកគេ។ បន្ទាប់មកថ្ងៃមួយយ៉ូហានបាទីស្ទបានឃើញព្រះយេស៊ូវដើរឆ្លងកាត់ទីនោះ រួចគាត់ក៏ពោលថានោះគឺជាព្រះយេស៊ូវគឺជាកូនចៀមនៃព្រះ! មនុស្សគ្រប់គ្នាមិនទាន់បានដឹងពីការនេះនោះទេ។

អនទ្រេនិងសិស្សរបស់លោកយ៉ូហានបាទីស្ទផ្សេងទៀតបានដើរតាមព្រះយេស៊ូវបន្ទាប់ពីលឺថា ព្រះយេស៊ូវគឺជាកូនចៀមនៃព្រះ។ បន្ទាប់ពីបានចំណាយពេលជាមួយព្រះយេស៊ូវមួយថ្ងៃ អនទ្រេបានដឹងថាគាត់បានរកឃើញព្រះមេស្ស៊ី ហើយគឺជាម្នាក់ដែលមនុស្សគ្រប់គ្នាកំពុងតែទន្ទឹងរងចាំ! ដោយមិនមានការស្ទាក់ស្ទើរអ្វីទាំងអស់អនទ្រេគឺជាមនុស្សដំបូងគេ ដែលបានរត់ទៅរកបងប្រុសរបស់គាត់គឺស៊ីម៉ូន ដើម្បីប្រាប់ថាគាត់បានរកឃើញព្រះមេស្ស៊ីហើយ។ ស៊ីម៉ូនបានឆ្លើយតបយ៉ាងលឿននឹងបានទៅជាមួយអនទ្រេដើម្បីជួបព្រះយេស៊ូវ ទីបំផុតគេក៏បានជួបកូនចៀមនៃព្រះ! ហើយនៅទីនោះព្រះយេស៊ូវបានប្តូរឈ្មោះ ស៊ីម៉ូនទៅជាពេត្រុស។

ការនិយាយថាព្រះយេស៊ូវគឺជាកូនចៀមនៃព្រះ គឺមានន័យថាព្រះយេស៊ូវបានជម្រះនូវអំពើបាបរបស់មនុស្សហើយបានថ្វាយកូនចៀមនៃព្រះ សម្រាប់ការអត់ទោសនៃអំពើបាបរបស់ពួកគេ។ ការបង្ហូរឈាមរបស់កូនចៀមគឺជាសញ្ញាបញ្ជាក់ពីការអត់ទោស។ ប៉ុន្តែនៅក្នុងច្បាប់នៃការថ្វាយកូនចៀម គឺត្រូវតែសម្លាប់កូនចៀមនោះ។ ព្រះយេស៊ូវគឺកូនចៀមនៃព្រះ ទ្រង់បានលះបង់ជីវិតសម្រាប់ពួកយើងរាល់គ្នា។ ព្រះយេស៊ូវបានលះបង់ជីវិតរបស់ទ្រង់ដូច្នេះពួកយើងទាំងអស់គ្នាត្រូវបានសង្គ្រោះ។

អ្នកគឺពិតជាពិសេសខ្លាំងណាស់សម្រាប់ព្រះ។ ជាការពិតអ្នកគឺពិសេស ទើបព្រះបញ្ជូនព្រះរាជបុត្រាតែមួយរបស់ទ្រង់គឺ ព្រះយេស៊ូវមកទទួលទោសសម្រាប់អំពើបាបរបស់អ្នក។ ជំនួសឲ្យការទទួលទោសព្រះយេស៊ូវចង់ឲ្យអ្នកសម្រាក និងទទួលបាននូវសន្តិភាពនៅពេលដែលអ្នកមករកទ្រង់។ ព្រះយេស៊ូវបានក្លាយទៅជាកូនចៀមនៃព្រះសម្រាប់អ្នក ពីព្រោះថាទ្រង់មិនមានបាបអ្វីសោះ។ អ្នកពិតជាពិសេសខ្លាំងណាស់ ដែលព្រះយេស៊ូវសព្វព្រះទ័យក្នុងការសុគតសម្រាប់អ្នក។ យើងសូមអរព្រះគុណព្រះអម្ចាស់នៅថ្ងៃនេះ ដោយព្រោះកូនចៀមនៃព្រះទើបយើងរាល់គ្នាបានសង្គ្រោះ!

## ៦. សំនួរពិភាក្សា

១. តើយ៉ូហានបាទីស្ទបាននិយាយអ្វីនៅពេលដែលគាត់បានឃើញព្រះយេស៊ូវឆ្លងកាត់ទីនោះ?

*គាត់បាននិយាយថា ព្រះយេស៊ូវគឺជាកូនចៀមនៃព្រះ*

២. តើអនទ្រេបានធ្វើដូចម្ដេចនៅពេលដែលរកឃើញថាព្រះយេស៊ូវគឺជាព្រះមេស្ស៊ីជាកូនចៀមនៃព្រះនោះ?

*គាត់បានរត់ចេញទៅរកបងប្រុសរបស់គាត់គឺ ពេត្រុស*

៣. តើវាមានន័យដូចម្ដេចនៅពេលដែលគេនិយាយថាព្រះយេស៊ូវជាកូនចៀមនៃព្រះ?

*វាមានន័យថា ព្រះយេស៊ូវបានជម្រះនូវអំពើបាបរបស់យើង*

៤. តើអ្នកដឹងដោយរបៀបណាថា ព្រះយេស៊ូវគិតថាអ្នកជាមនុស្សពិសេសនោះ?

*ព្រះយេស៊ូវបានសុគតសម្រាប់យើង ប្រៀបដូចជាកូនចៀមនៃព្រះដើម្បីសង្គ្រោះពួកយើង*

## ៧. ល្បែងកំសាន្ត «ស្វែងរកកូនចៀម»

**សម្ភារៈដែលត្រូវការៈ** រូបភាព គោ តោ លា និងកូនចៀម (សូមមើលនៅទំព័រខាងក្រោម)

១.ព្រីនរូបភាពសត្វទាំង៤ហើយបិតវានៅលើជញ្ជាំងនៃថ្នាក់រៀនកន្លែងផ្សេងៗគ្នា និងបិតវាពាក់កណ្ដាលទៀត ដើម្បីកុំឲ្យកុមារមើលឃើញរូបនៅខាងក្នុង។



២. ចាក់បទចម្រៀងហើយឲ្យកុមារទាំងអស់រាំជារង្វង់ នៅពេលដែលចម្រៀងឈប់កុមារត្រូវរត់ទៅប៉ះរូបភាពណាមួយក៏បាន ដែលពួកគេចង់ បានហើយបើករូបនោះឲ្យពួកគេឃើញ។ ប្រសិនបើកុមារណាជ្រើសរើស បានរូបកូនចៀម នោះពួកគេនឹងឈ្នះល្បែងនេះ។

៣. គ្រូបន្តចាក់បទចម្រៀងហើយសិស្សទាំងអស់បន្តរាំទៀត។ នៅពេល ដែលកុមារទាំងអស់កំពុងរវល់ក្នុងការរាំ ជំនួយការគ្រូត្រូវជួយប្ដូរទីតាំងរូបទាំងអស់នោះ។

៤. លេងល្បែងនេះ៥ដង។ ប្រសិនកុមារណាម្នាក់អាចចាប់ចំរូបរបស់កូនចៀមទាំង ៥ដង នោះគេនឹងទទួលបានកាដូរ។

៥. តាមរយៈល្បែងនេះ សូមពន្យល់កុមារថា កូនចៀមតំណាងឲ្យព្រះយេស៊ូវគ្រីស្ទ ពីព្រោះថាទ្រង់ជាកូនចៀមនៃព្រះ។ វាគឺពិតជាពិបាកសម្រាប់មនុស្សមួយចំនួនក្នុងការស្វែងរកព្រះយេស៊ូវ ប៉ុន្តែព្រះយេស៊ូវគឺតែងតែនៅជាមួយពួកយើងជានិច្ចដូចជាកូនចៀមនៃព្រះ ដែលបានសុគតសម្រាប់ពួកយើង។

## ៨. ខគម្ពីរចងចាំ យ៉ូហាន១:៣៦

**៩. ហត្ថកម្ម** «ម៉ាស់មុខចៀម»

**សម្ភារៈដែលត្រូវការ៖** ចានក្រដាស កន្ត្រៃ កាវបិទ ដុំសំឡី ដងឈើការ៉េម និងក្រដាសពណ៌ផ្កាឈូក



១. កាត់ផ្នែកកណ្តាលនៃចានក្រដាស

២. កាត់ត្រចៀកចៀមពីក្រដាសពណ៌ផ្កាឈូក

៣. បិតដុំសំឡីជាមួយរុំជុំវិញចានដែលបានកាត់រួច

៤. បិតត្រចៀកចៀមនៅផ្នែកខាងលើ

៥. បិតដងឈើការ៉េមនៅផ្នែកខាងក្រោម

៦. ឲ្យកុមារដាក់ម៉ាស់មុខចៀម ពីលើមុខរបស់ពួកគេហើយនិយាយថា "កូនចៀមនៃព្រះបានសង្គ្រោះពួកយើង!"

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*



------------------ បត់ទីនេះ ------------------



------------------- បត់ទីនេះ -------------------



----------------- បត់ទីនេះ -----------------



------------------ បត់ទីនេះ ------------------